# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

រៀងរាល់ត្រីមាស ទំព័រនេះគូសបញ្ជាក់ពីដំណើរការសេដ្ឋកិច្ចរបស់ប្រទេសមានសេដ្ឋកិច្ចខ្លាំងៗក្នុងពិភពលោក និងរបស់ប្រទេសភាគច្រើននៅអាស៊ីខាងកើត ។ ការវិវត្តសេដ្ឋកិច្ចនៅប្រទេសទាំងនោះ មានជាប់ទាក់ទងច្រើនណាស់ដល់សេដ្ឋកិច្ចប្រទេសកម្ពុជា ។

ផសស ពិត របស់សហរដ្ឋអាមេរិក នៅត្រីមាសទី៣ ឆ្នាំ២០០៧ កើនឡើង ៤,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ កំណើននេះឆ្លុះបញ្ចាំងជាសំខាន់ពីការចូលរួមចំណែកជាវិជ្ជមាននៃការនាំចេញ ចំណាយប្រើប្រាស់ផ្ទាល់ខ្លួន វិនិយោគលើស្តុកឯកជន បរិក្ខារ និង សូហ្វវែរ ចំណាយរដ្ឋាភិបាលសហព័ន្ធ ចំណូល-ចំណាយរបស់អនិវាសជន ព្រមទាំងចំណាយរបស់រដ្ឋាភិបាលនៅតាមរដ្ឋ និងនៅតាមមូលដ្ឋាន ។ ផសស ពិត នៅតំបន់អឺរ៉ូក្នុងត្រីមាសទី៣ ឆ្នាំ២០០៧ កើន ២,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និងកើន ០,៨% ធៀបនឹងត្រីមាសមុន។ ផសស ពិត នៅជប៉ុន កើន ១,៩% ធៀបនឹងឆ្នាំមុន និង កើន ០,៣% ធៀបនឹងត្រីមាសមុន ។

សេដ្ឋកិច្ចប្រទេសចិននៅត្រីមាសទី៣ ឆ្នាំ២០០៧ កើនឡើង ១១,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែវាមានកំណើនយឺតបន្តិច ធៀបនឹងត្រីមាសទី២ ។ រឿងនេះឆ្លុះបញ្ចាំងជាចំបងពីកំណើនយ៉ាងខ្លាំងក្នុងវិស័យឧស្សាហកម្ម សេវាកម្ម ការនាំចេញ និង វិនិយោគទុន ។ ផសស ពិតរបស់កូរ៉េខាងត្បូង នៅត្រីមាសទី៣ កើន ៥,២% ធៀបនឹងឆ្នាំមុន និង កើន ១,៣% ធៀបនឹងត្រីមាសមុន ។ កំណើនផលិតកម្ម និងសេវាកម្ម បានបង្កើន ល្បឿន រីឯកំណើនក្នុងវិស័យសំណង់បានថយល្បឿនមកវិញ ។ គិតតាមតួលេខចំណាយ ការនាំចេញទំនិញ បន្តមានអត្រាកំណើនខ្ពស់ កំណើនចំណាយប្រើប្រាស់ឯកជនកាន់តែស្ទុះលឿន រីឯវិនិយោគខាងសំណង់ និងបរិក្ខារមានការថយចុះ ។ ផសស ពិត នៅតៃវ៉ាន់ និង ហុងកុង ក្នុងត្រីមាសទី៣ ឆ្នាំ២០០៧ កើន ៦,៩% និង ៦,២% ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំមុន ។

នៅត្រីមាសទី៣ ឆ្នាំ២០០៧ សេដ្ឋកិច្ចម៉ាឡេស៊ី កើន ៦,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ដំណើរការសេដ្ឋកិច្ចខ្លាំងក្លា បណ្តាលមកពីកំណើនសេវាកម្ម (១០,៥%) និង ផលិតកម្ម (៣,៤%)។ សេដ្ឋកិច្ចសិង្ហបុរី កើន ៨,៩% នៅត្រីមាសទី៣ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ វិស័យដែលកើនលឿនជាងគេគឺ ផលិតកម្ម (នាំមុខគេដោយជីវឱសថ និងវិស្វកម្មខាងដឹកជញ្ជូន) សេវាកម្មហិរញ្ញវត្ថុ និង សំណង់ ។ ផសស ពិត នៅថៃក្នុងត្រីមាសទី៣ ឆ្នាំ២០០៧ កើន ៤,៨% ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំ ២០០៦ ។ កសិកម្ម កើន ១,៧% គឺថយចុះពីកំណើន ៧,៥% នៅត្រីមាសមុន រីឯផលិតផលសំរេចមិនមែនកសិកម្ម កើន ៥,០% ធៀបនឹងកំណើន ៤,០% កាលពីត្រីមាសមុន ។

## អតិផរណាក្នុងពិភពលោក និង អត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិ

នៅត្រីមាសទី៣ ឆ្នាំ២០០៧ ថ្លៃទំនិញប្រើប្រាស់នៅសហរដ្ឋអាមេរិកកើន ២,៤% ធៀបនឹងកាលពីមួយឆ្នាំមុន ដោយសារ កំណើនថ្លៃម្ហូបអាហារ ការថែទាំសុខភាព ផ្ទះ ការអប់រំ ទូរគមនាគមន៍ និង ថាមពល ។ នៅតំបន់អឺរ៉ូ អតិផរណាមានអត្រា ១,៩% គឺដូចគ្នានឹងកាលពីត្រីមាសមុន ។ ព័ត៌មានដែលទទួលបានវាបង្ហាញថា កត្តាថាមពល ហើយជាពិសេសការធៀបនឹងឆ្នាំមុនដែលមានការថយចុះតំលៃថាមពល បានរួមចំណែកបង្កើនតួលេខប៉ាន់ស្មានកំណើននៅត្រីមាសទី៣ ឆ្នាំ២០០៧ ។ ក្នុងអំឡុងពេលដូចគ្នា ថ្លៃទំនិញប្រើប្រាស់នៅជប៉ុន ធ្លាក់ចុះ ០,១% ធៀបនឹងឆ្នាំមុន ហើយវាបានធ្លាក់ចុះអស់បីត្រីមាសជាប់ៗគ្នាមកហើយ ។ រឿងនេះឆ្លុះបញ្ចាំងជាសំខាន់ពីការចុះថ្លៃខ្សែទស្សនកិច្ចទៅក្រៅប្រទេស និងបរិក្ខារអេឡិចត្រូនិកប្រើប្រាស់ក្នុងគ្រួសារ ។ ប៉ុន្តែអត្រានៃការប្រែប្រួលមានកំរិតទាបជិតស្មើសូន្យ ប្រសិនបើគេមិនគិតបញ្ចូលនូវថ្លៃផលិតផលប្រេងឥន្ធនៈ និងកត្តាពិសេសផ្សេងៗទៀតនោះទេ ។

នៅត្រីមាសទី៣ ឆ្នាំ២០០៧ នៅទីផ្សារប្តូរប្រាក់អន្តរជាតិ ដុល្លារUS ធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុចំបងៗ ។ ទល់នឹងប្រាក់យ៉េនជប៉ុន ដុល្លារUS ប្តូរបាន ១១៧,៧យ៉េន/ដុល្លារUS គឺធ្លាក់ថ្លៃពី ១២០,៨យ៉េន/ដុល្លារUS នៅត្រីមាសទី២ ។ ដុល្លារUS ធ្លាក់ថ្លៃទល់នឹងប្រាក់អឺរ៉ូ ប្រាក់យ៉ុនចិន និងប្រាក់វ៉ុនកូរ៉េខាងត្បូង ដោយប្តូរបាន ០,៧៣អឺរ៉ូ/ដុល្លារUS, ៧,៥៥យ៉ុន/ដុល្លារUS, និង ៩២៧វ៉ុន/ដុល្លារUS ធៀបនឹងត្រីមាសទី២ ដែលមានអត្រា ០,៧៤អឺរ៉ូ/ដុល្លារUS, ៧,៦៨យ៉ុន/ដុល្លារUS, និង ៩២៩វ៉ុន/ដុល្លារUS ។ ដុល្លារUS ធ្លាក់ថ្លៃដោយសារពួកពាណិជ្ជកររំពឹងថា ធនាគារកណ្តាលអាមេរិក នឹងបន្តកាត់បន្ថយអត្រាការប្រាក់ដើម្បីទប់ទល់ការធ្លាក់ចុះសេដ្ឋកិច្ច ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី៣ ឆ្នាំ២០០៧ ថ្លៃប្រេងឆៅ សណ្តែកសៀង អង្ករ ប្រេងឆៅ និងម៉ាស៊ូត កើនឡើង រីឯថ្លៃពោត និង សាំង ធ្លាក់ចុះ។ ប្រេងឆា លក់បាន ៧៤៥,៨៦ដុល្លារUS/តោន ដែលកើនពី ៦៩១,៤៤ដុល្លារUS/តោន នៅត្រីមាសទី២ ខណៈពេលដែលពោត និង សណ្តែកសៀង លក់បាន ១៣៩,៨១ដុល្លារUS/តោន និង ២៩៩,៩៩ដុល្លារUS/តោន ។ នៅទីផ្សារក្រុងបាងកកអង្ករ Thai 100% B លេខពីរ លក់ថ្លៃ ៣០៤,៧៥ដុល្លារUS/តោន ដែលកើនពី ២៨៣,៨៩ដុល្លារUS/តោន នៅត្រីមាសទី២ ។ ថ្លៃប្រេងឆៅ នៅត្រីមាសទី៣ កើន ១១% ធៀបនឹងត្រីមាសមុន ដល់ ៧២,៤៨ដុល្លារUS/ធុង ។ ថ្លៃសាំង ថយចុះ ៤,២% ធៀបនឹងត្រីមាសមុន មកត្រឹម ៥៥,៤៩សេន/លីត្រ រីឯថ្លៃម៉ាស៊ូត កើន ៥,០% ដល់ ៥៥,៦២សេន/លីត្រ ។

*រៀបរៀងដោយ លោក ហ៊ីង វុត្ថា និង លោក ភីម រុនស៊ីណារិទ្ធិ*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

*តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)*

| | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 4.8 | 7 | 7.7 | 13.4 | 10.6 | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 3.8 | 4.9 | 5.1 | 5.6 | 5.4 | 5.5 | 6.1 | - | - | - |
| ម៉ាឡេស៊ី | 5.6 | 5.4 | 7 | 5.2 | 5.9 | 5.8 | 5.7 | 5.3 | 5.7 | 6.7 |
| សិង្ហបុរី | 2.6 | 1.4 | 8.5 | 5.7 | 7.7 | 7.1 | 7.0 | 6.0 | 8.2 | 8.9 |
| ថៃ | 6.1 | 6.9 | 6 | 4.5 | 4.8 | 4.7 | 4.2 | 4.3 | 4.4 | 4.8 |
| វៀតណាម | 6.7 | 7 | 7.5 | 8.4 | 8.1 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 8.1 | 9.9 | 9.5 | 9.6 | 10.5 | 10.4 | 10.7 | 11.1 | 11.5 | 11.4 |
| ហុងកុង | 5.0 | 3.2 | 8.3 | 6.5 | 6.6 | 6.8 | 7.0 | 5.6 | 6.9 | 6.2 |
| កូរ៉េខាងត្បូង | 6.1 | 3 | 4.7 | 4.7 | 5.0 | 4.8 | 5.0 | 4.0 | 4.5 | 5.2 |
| តៃវ៉ាន់ | 4.2 | 3.1 | 5.7 | 4.1 | 4.6 | 5.0 | 4.0 | 4.1 | 5.07 | 6.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 0.7 | 0.5 | 1.8 | 1.5 | 2.7 | 2.6 | 3.3 | 3.0 | 2.5 | 2.7 |
| ជប៉ុន | 0.4 | 2.6 | 3.4 | 2.5 | 2.1 | 2.7 | 2.3 | 2.2 | 2.3 | 1.9 |
| សហរដ្ឋអាមេរិក | 2.4 | 3.1 | 4.4 | 3.7 | 3.3 | 3.3 | 3.1 | 1.5 | 3.8 | 4.9 |

*Sources: International Monetary Fund, Economist and countries' statistic offices*

*តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)*

| | 2002 | 2003 | 2004 | 2005 | 2006 | 2006 Q3 | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 3.2 | 1.2 | 4.0 | 5.8 | 4.7 | 4.9 | 3.4 | 3.0 | 4.6 | - |
| ឥណ្ឌូនេស៊ី | 13.2 | 8.3 | 8.3 | 10.5 | 13.4 | 14.9 | 6.1 | 6.4 | - | - |
| ម៉ាឡេស៊ី | 1.8 | 1.1 | 1.6 | 3.1 | 3.7 | 3.6 | 3.1 | 2.6 | 1.4 | 1.8 |
| សិង្ហបុរី | -0.4 | 0.5 | 1.7 | 0.5 | 1.0 | 0.7 | 0.6 | 0.5 | 1.0 | 2.7 |
| ថៃ | 0.6 | 1.8 | 2.7 | 4.5 | 4.7 | 3.6 | 3.3 | 2.4 | 1.9 | 1.7 |
| វៀតណាម | 3.8 | 3.1 | 7.8 | 8.2 | - | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | -0.7 | 1.2 | 3.9 | 1.8 | 1.5 | 1.4 | 1.8 | 2.6 | 3.6 | 6.1 |
| ហុងកុង | -3.0 | -2.6 | -0.4 | 1.1 | 2.2 | 2.3 | 2.2 | 1.7 | 1.3 | 1.6 |
| កូរ៉េខាងត្បូង | 2.7 | 3.5 | 3.5 | 2.8 | 2.4 | 2.5 | 2.4 | 2.0 | 2.4 | 2.3 |
| តៃវ៉ាន់ | -0.2 | -0.3 | 1.6 | 2.3 | 0.6 | -0.3 | -0.1 | 1.0 | 0.3 | 1.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | 0.0 | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.1 | 2.2 | 2.2 | 2.1 | 2.1 | 1.8 | 1.9 | 1.9 | 1.9 |
| ជប៉ុន | -0.9 | -0.3 | Nil | -0.3 | 0.5 | 0.6 | 0.3 | -0.1 | -0.1 | -0.1 |
| សហរដ្ឋអាមេរិក | 1.6 | 2.3 | 2.7 | 3.4 | 3.2 | 3.3 | 1.9 | 2.4 | 2.7 | 2.4 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

*តារាង៣. អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)*

| | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3912.1 | 3973 | 4016.3 | 4092.5 | 4103.2 | 4125.0 | 4111.3 | 4046.7 | - | - |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9311 | 8577 | 8938 | 9705 | 9134 | 9122 | 9125 | 9107 | - | - |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.79 | 3.67 | 3.67 | 3.62 | 3.50 | 3.43 | 3.46 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.79 | 1.74 | 1.69 | 1.66 | 1.59 | 1.58 | 1.56 | 1.53 | 1.52 | 1.52 |
| ថៃ (បាត) | 42.9 | 41.5 | 40.2 | 40.2 | 37.9 | 37.7 | 36.5 | 33.9 | 32.5 | 31.4 |
| វៀតណាម (ដុង) | 15,280 | 15,510 | - | 15,859 | 15,994 | 16,015 | 16,077 | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ុន) | 8.28 | 8.28 | 8.28 | 8.19 | 7.97 | 7.97 | 7.86 | 7.76 | 7.68 | 7.55 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.78 | 7.79 | 7.78 | 7.77 | 7.78 | 7.78 | 7.81 | 7.82 | 7.81 |
| កូរ៉េខាងត្បូង (វ៉ុន) | 1251 | 1192 | 1145 | 1024 | 955 | 955 | 938 | 939 | 929 | 927 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 34.5 | 34.4 | 33.6 | 32.1 | 32.5 | 32.8 | 32.8 | 32.9 | 33.1 | 32.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 1.06 | 0.89 | 0.80 | 0.80 | 0.80 | 0.78 | 0.78 | 0.76 | 0.74 | 0.73 |
| ជប៉ុន (យ៉េន) | 125.4 | 115.9 | 108.2 | 110.2 | 116.4 | 116.3 | 117.8 | 119.4 | 120.8 | 117.7 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

*តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០១-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)*

| | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 |
| ពោត (US No. 2) - US ($/តោន) | 89.98 | 95.42 | 110.65 | 89.19 | 111.04 | 108.67 | 140.18 | 154.33 | 146.10 | 139.81 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 353.91 | 402.03 | 427.47 | 381.32 | 433.85 | 446.85 | 494.92 | 552.06 | 691.44 | 745.86 |
| អង្ករ (Thai 100%B) – បាងកក ($/តោន) | 178.59 | 182.22 | 221.67 | 262.88 | 282.00 | 289.91 | 279.10 | 294.17 | 283.89 | 304.75 |
| សណ្ដែកសៀង (US No. 1) – US ($/តោន) | 182.58 | 218.86 | 262.03 | 224.25 | 213.88 | 207.38 | 230.17 | 255.33 | 259.95 | 299.99 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 23.9 | 26.8 | 33.5 | 50.14 | 61.58 | 67.00 | 56.39 | 54.21 | 65.41 | 72.48 |
| សាំង – US Gulf Coast (សេន/លីត្រ) | 19.1 | 23 | 30.9 | 42.19 | 47.70 | 52.70 | 41.02 | 41.71 | 57.93 | 55.49 |
| ម៉ាស៊ូត (ស្តាន់ដ័រតិច លេខ២) – US Gulf Coast (សេន/លីត្រ) | 17.85 | 21.63 | 29.48 | 44.35 | 51.35 | 55.66 | 46.11 | 45.61 | 53.90 | 56.62 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

*តទៅទំព័រទី ៥* **របាយការណ៍សង្ខេប...**

**កំណត់សំគាល់**

១. នៅឆ្នាំ២០០៥ ក្រសួងនេះ បានបែងចែកជា ក្រសួងការងារ (MLVT) និង ក្រសួងសង្គមកិច្ច យុវជន និងយុវនីតិសម្បទា (MOSAVY) ។

២. តួលេខ មានខ្ពស់ជាងនៅប្រទេសថៃ និងវៀតណាម ដែលមានការនាំពលករចេញយ៉ាងច្រើន ។ យោងតាម Dang (២០០៧) នៅវៀតណាម ក្រុមហ៊ុនជ្រើសរើសពលករដែលមានអាជ្ញាប័ណ្ណមិនតំរូវឱ្យដាក់ប្រាក់ដំកល់អ្វីទេ ។

៣. ព័ត៌មានបានមកពីកិច្ចប្រជុំជាមួយសមាជិករបស់បណ្ដាញ NGO ។

៤. ជំនួបជាមួយមន្ត្រីថៃនៅក្រសួងការងារ នៅថ្ងៃទី១៥ វិច្ឆិកា ២០០៧ ។

៥. កម្ពុជា បានសំរេចផ្លាស់ប្ដូរយ៉ាងរហ័សទៅប្រើប្រាស់លិខិតឆ្លងដែនទិន្នន័យអេឡិចត្រូនិក (ប្រហែលជាប្រទេសដំបូងនៅក្នុងតំបន់ដែលធ្វើរឿងនេះ) ដោយមិនបានគិតពីចំណាយដ៏លើសលប់ ។ ក្រុមការងារម៉ាឡេស៊ី ៦នាក់ ជាអ្នកដាក់បញ្ចូលបន្ទុះទិន្នន័យ និងទទួលបានកំរៃ ២០ដុល្លារ សំរាប់លិខិតឆ្លងដែនមួយ ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទីបី ២០០៧ វិនិយោគ សកម្មភាពសាងសង់ ទេសចរណ៍ និង ពាណិជ្ជកម្ម មានកំណើនវិជ្ជមាន ។ វិនិយោគកើនឡើងជាខ្លាំង ធៀបនឹងត្រីមាសមុន ហើយរួមចំណែកយ៉ាងច្រើនដល់ដល់កំណើនសេដ្ឋកិច្ច ។ ការអនុម័តគំរោងសាងសង់ និងចំនួនភ្ញៀវមកដល់ កើនឡើងតិចតួច ហើយ ឱនភាពពាណិជ្ជកម្មបានកែលំអគួរសមឡើងវិញ ។

នៅត្រីមាសទីបី អនុមតិគំរោងវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់សរុប (៣៧គំរោង) កើនដល់ ១១៥៦,៩លានដុល្លារ រឺកើនជាមធ្យមមួយជាបួន ធៀបនឹងតំលៃនៅត្រីមាសដូចគ្នា ឆ្នាំ២០០៦។ គំរោងវិស័យឧស្សាហកម្មបានអនុម័ត កើន ០,៩% ដល់ ១៨៧,២លានដុល្លារ (២៥គំរោង) ដែលបានមកពីអនុវិស័យកាត់ដេរ ។ និន្នាការតាមរដូវនៃការអនុម័តគំរោងសំរាប់អនុវិស័យកាត់ដេរ បង្ហាញថា ត្រីមាសទីបី គឺជាអំឡុងពេលដែលវាតែងកើនឡើងជារៀងរាល់ឆ្នាំ ។ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់នៃអនុវិស័យកាត់ដេរ កើន ៧៦% ដល់ ៤០,៧លានដុល្លារ សំរាប់ ១១គំរោង ។ ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ អនុមតិគំរោងវិនិយោគខាងរ៉ែ កើនមួយជាបួន ដល់ ១១,២លានដុល្លារ រីឯខាងថាមពលបានកើនពីសូន្យ ដល់ ៣,១លានដុល្លារ ។ ប្រសិនបើគំរោងអនុមតិខាងឧស្សាហកម្មទាំងអស់ អនុវត្តបានជាក់ស្តែង វានឹងបង្កើតបានសរុប ២៩.២០៨ការងារថ្មី ក្នុងនេះ ៧៣% ស្ថិតក្នុងអនុវិស័យកាត់ដេរ ។ វិនិយោគលើវិស័យកសិកម្មក៏កើនឡើងដែរតាំងពីកំរិតសូន្យនៅឆ្នាំមុន ទៅដល់ ១២,០លានដុល្លារ សំរាប់គំរោងកសិ-ឧស្សាហកម្មពីរ ដែលផ្តល់ការងារដល់កម្មករ ១០០០នាក់ ។ គំរោងវិស័យសេវាកម្មបានអនុម័ត កើនមួយជាដប់ធៀបនឹងឆ្នាំមុន ដល់ ៩៥៧,៧លានដុល្លារ (១០គំរោង)។ រីឯអនុមតិវិនិយោគលើវិស័យសេវាកម្មវិញ ខាងទេសចរណ៍មានដល់ ៦៨% និងទូរគមនាគមន៍ ២៣% ហើយគំរោងទាំងនេះរំពឹងថា នឹងផ្តល់ការងារដល់កម្មករ ៨៧៦៧នាក់ ។

ការវិនិយោគកើតមាននៅតាមទីក្រុង ជាពិសេសក្រុងភ្នំពេញ ។ ដោយសារនៅទីក្រុង ចំនួនប្រជាជន និងអាជីវកម្មផ្សេងៗបន្តកើនឡើងឥតឈប់ឈរ សកម្មភាពសាងសង់ក៏រីកដុះដាលទាំងការសាងសង់ថ្មី និងការជួសជុលសំណង់មានស្រាប់ ហើយសេវាកម្មអចលនទ្រព្យក៏រីកលូតលាស់តាមនោះដែរ ។ សំណង់ផ្ទះល្វែងនៅក្នុងក្រុង និងជាយក្រុង មានសន្ទុះលឿនជាងសំណង់ឯទៀតៗ ។ នៅត្រីមាសទីបី ២០០៧ អនុមតិគំរោងសាងសង់ទាំងអស់នៅភ្នំពេញ កើន ២៤% ធៀបនឹងត្រីមាសមុន ដល់ ១៧៩,៧លានដុល្លារ ក្នុងនេះផ្ទះល្វែងមាន ៦៥% រឺកើនឡើងមួយជាបីធៀបនឹងត្រីមាសមុន ។ អនុមតិគំរោងសាងសង់ភូមិគ្រឹះនិងផ្ទះ មានចំនួន ២១,៧លានដុល្លារ រឺថយចុះ ៤,៨% ហើយសំណង់ផ្សេងៗទៀត ធ្លាក់ចុះ ៥៤% មកត្រឹម ៤០,៦ លានដុល្លារ ។

ឱនភាពពាណិជ្ជកម្មមានកំរិត ៣០,៣លានដុល្លារ គឺប្រសើរជាងត្រីមាសមុនដែលមានទំហំដល់ ២០៨,១លានដុល្លារ ប៉ុន្តែនៅអន់ជាងត្រីមាសដូចគ្នា ឆ្នាំ២០០៦ ដែលមានអតិរេកដល់ ២៣,២លានដុល្លារ ។ ក្នុងអំឡុង ១២ខែនេះ ការនាំចេញ និងនាំចូលសរុប បានកើនឡើងបង្គួរ ។

នៅត្រីមាសទីបី ២០០៧ ការនាំចេញរបស់កម្ពុជា កើន ១០% ធៀបនឹងត្រីមាសទីបី ២០០៦ ដល់ ៨៩០,៨លានដុល្លារ ។ វិស័យកាត់ដេរជាកត្តាចំបងដែលបណ្តាលអោយមានកំណើននេះ ដោយវារួមចំនែក ៩៥% នៃការនាំចេញសរុប និងកើនបាន ៨,២% ធៀបនឹងឆ្នាំមុន ដល់ ៨៤៦,១លានដុល្លារ ។ ការនាំចេញឈើថយចុះ ៩៩% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ មកត្រឹម ០,០១លានដុល្លារ, ការនាំចេញត្រី ធ្លាក់ចុះ ២៧% មកត្រឹម ១,២លានដុល្លារ ហើយការនាំចេញកៅស៊ូ ធ្លាក់ចុះ ១៤% មកត្រឹម ១១,៧លានដុល្លារ ។ វិស័យកសិកម្មរួមចំនែកតិចតួចណាស់ដល់ការនាំចេញរបស់កម្ពុជា រីឯវិស័យកាត់ដេរវិញ វាជាស្នូលនៃកំណើនការនាំចេញ ហើយបានផ្តល់ការងារដល់កំលាំងពលកម្មមួយភាគធំ។ ប៉ុន្តែទីផ្សារកាត់ដេរកាន់តែមានការប្រកួតប្រជែងខ្លាំង ពីព្រោះប្រទេសមួយចំនួន ដូចជា ចិន និង វៀតណាម គេមានកំរិតតំលៃអាចប្រកួតប្រជែងបានច្រើនធៀបនឹងកម្ពុជា ដូចជា តំលៃពលកម្ម ជាដើម។

ផលិតកម្មក្នុងស្រុក មិនអាចផ្គត់ផ្គង់គ្រប់គ្រាន់តាមតំរូវការក្នុងស្រុកទេ ដូច្នេះការនាំចូលបន្តកើនឡើង ។ នៅត្រីមាសទីបី ២០០៧ ការនាំចូលសរុបមានតំលៃ ៩២៤,៥លានដុល្លារ រឺកើន ១៨% ធៀបនឹងឆ្នាំមុន។ ការនាំចូលស៊ីម៉ង់ត៍ ដែក និងក្រណាត់ ធ្លាក់ចុះ ប៉ុន្តែការនាំចូលផលិតផលប្រេងកាតកើនឡើង ១៤% ដល់ ៧១,០លានដុល្លារ ។ ការនាំចូលស៊ីម៉ង់ត៍ធ្លាក់ចុះ ១០% មកត្រឹម ១៤,៣លានដុល្លារ, ការនាំចូលដែកថយចុះ ៤៤% មកត្រឹម ៩,៩លានដុល្លារ ហើយការនាំចូលក្រណាត់ថយចុះអស់ ៩៩% មកត្រឹម ១,៩លានដុល្លារ ។

នៅត្រីមាសទីបី ២០០៧ ភ្ញៀវមកដល់កម្ពុជា កើនឡើងប្រហែល ១៧% ធៀបនឹងត្រីមាសទីបី ២០០៦ ដល់ ៤៣១,៨១៩នាក់ ។ ភ្ញៀវមកដល់តាមផ្លូវអាកាសកើន ២៤% ដល់ ២៧៨,៥២៣នាក់ ដែលក្នុងនោះអាកាសយានដ្ឋាន ភ្នំពេញទទួលបាន ៤៥% និងអាកាសយានដ្ឋានសៀមរាប ៥៥% ។ ភ្ញៀវមកដល់តាមផ្លូវគោកកើន ៥,២% ដល់ ១៤៤,៥៨២នាក់ រីឯភ្ញៀវមកដល់តាមផ្លូវទឹកថយចុះ ៣,៣% មកត្រឹម ៨៧១០ នាក់។ ខេត្ត

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

សៀមរាប ជាគោលដៅមានប្រជាប្រិយភាពខ្លាំងជាងគេនៅកម្ពុជា ។ នៅត្រីមាសទីបី ខេត្តសៀមរាបទទួលបាន ៤៤% នៃចំនួនភ្ញៀវមកដល់សរុប ។ ភ្ញៀវមកសំរាកលំហែមានចំនួន ៣៥៩,៧៣០នាក់ រឺកើន ១២% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦។ កូរ៉េខាងត្បូងជាប្រទេសនាំមុខគេខាងទេសចរមកធ្វើទស្សនកិច្ចនៅកម្ពុជា ហើយបន្ទាប់មកគឺ ជប៉ុន និង វៀតណាម ។

## អត្រាអតិផរណា និង អត្រាប្តូរប្រាក់បរទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុបនៅកម្ពុជា ផ្សព្វផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិសំរាប់ត្រីមាសទីបី កើន ១១,៩% ធៀបនឹងឆ្នាំមុន រឺ ៣,៤% ខ្ពស់ជាងកំណើននៅត្រីមាសមុន ។ ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិអាកុល កើន ១៦,៩% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ រីឯថ្លៃដឹកជញ្ជូន កើនបន្តិចបន្តួចត្រឹម ២,០% ។

នៅប្រទេសកម្ពុជា ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិអាកុល តំណាងអោយ ៥៨% នៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ។ ដូចនេះ ការឡើងថ្លៃម្ហូបអាហារជំរុញអោយមានអតិផរណាជាទូទៅ ។ បន្ថែមលើនេះទៀត ថ្លៃម្ហូបអាហារនៅលើសាកលលោកកើនយ៉ាងលឿន ហើយជះឥទ្ធិពលយ៉ាងខ្លាំងដល់កម្ពុជាដែលជាប្រទេសនាំចូលច្រើន ។ ឧទាហរណ៍ ម្ហូបអាហារនាំចូលពីថៃតំណាងឱ្យ ៦,៦% នៃទំនិញនាំចូលសរុបពីថៃមកកម្ពុជា ។ ដូចនេះ ម្ហូបអាហារនៅថៃដែលឡើងថ្លៃ ៤,៤% បានធ្វើអោយឡើងថ្លៃម្ហូបអាហារដែលកម្ពុជានាំចូលមក។

នៅត្រីមាសទីបី ២០០៧ ប្រាក់រៀលឡើងថ្លៃទល់នឹងប្រាក់ដុល្លារUS ១,៥% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ ដោយ ប្តូរបាន ៤០៨២,៣រៀល/ដុល្លារUS ប៉ុន្តែទល់នឹងប្រាក់បាតថៃ ប្រាក់រៀលធ្លាក់ថ្លៃ ១៨% មកត្រឹម ១៣០,០រៀល/បាត ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀលធ្លាក់ថ្លៃ ១,៦% ដោយប្តូរបាន ២៥,៣ រៀល/១០០ដុង ។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទីបី ២០០៧ រូបិយវត្ថុទូទៅ（M2）សរុប កើន ៥៣% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ ដល់ ៩៩០៨,២ ពាន់លានរៀល។ រូបិយវត្ថុ（M1）កើន ១២% ដល់ ១៧៤៩,៧ពាន់លានរៀល ក្នុងនេះប្រាក់រៀលចរាចរក្រៅធនាគារ មាន ៩៦% និងប្រាក់បញ្ញើចរន្តមាន ៤% ។ ប្រាក់រៀលកំពុងចរាចរ កើន ១១% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ ។ រូបិយវត្ថុផ្សេងៗ ដូចជា ប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើជារូបិយវត្ថុបរទេស មានចំនួន ៨១៥៨,៥ ពាន់លានរៀល រឺ កើន ៦៧% ។ ក្នុងចំណោមរូបិយវត្ថុផ្សេងៗ ប្រាក់បញ្ញើជារូបិយវត្ថុបរទេស មានចំនួន ៩៩% រឺកើន ៦៨% ធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០០៦ ។

កំណើនចំនួនរូបិយវត្ថុទូទៅ（M2）កើតចេញពីដំណើរប្រតិបត្តិការរវាងទ្រព្យសកម្មក្នុងស្រុក និងទ្រព្យសកម្មបរទេស ។ នៅត្រីមាសទីបី ឥណទានក្នុងស្រុក ដែលមានជា ឥណទានដល់រដ្ឋាភិបាលនិងវិស័យឯកជន ប្រាក់បញ្ញើរដ្ឋាភិបាល និងបំណុលផ្សេងៗទៀត កើន ៦០% ដល់ ៣៨២៩,៣ ពាន់លានរៀល ។ ឥណទានផ្តល់ដល់រដ្ឋាភិបាល កើន ១០% ដល់ ២៩៦,៧ ពាន់លានរៀល និងដល់វិស័យឯកជន កើន ៦៣% ដល់ ៥៣៧៦,៤ពាន់លានរៀល ។ ប្រាក់បញ្ញើរដ្ឋាភិបាល កើន ៥៩% ដល់ ១៨៤៣,៨ពាន់លានរៀល និងបំណុលផ្សេងៗ កើន ២៧% ដល់ ៣៦៨៩,១ពាន់លានរៀល ។ ទ្រព្យសកម្មបរទេសសុទ្ធ កើន ៤០% ដល់ ៩៧៦៧,៩ពាន់លានរៀល ។

## ស្ថានភាពក្រីក្រ_ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

នៅខែវិច្ឆិកា ២០០៧ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះភាគច្រើន បានកើនឡើង ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ។ ផ្ទុយទៅវិញ ប្រាក់ចំណូលរបស់ពលករកាត់ដេរ បានធ្លាក់ចុះ ។

ប្រាក់ចំណូលរបស់អ្នករត់ម៉ូតូឌុបកើន ៣៧% ដល់ ១៣.០៦០រៀល ដែលជាកំណើនប្រាក់ចំណូលខ្ពស់បំផុតរបស់ពួកគេ ចាប់តាំងពីអង្កេតបានចាប់ផ្តើមនៅឆ្នាំ២០០០ ។ ទោះបីប្រាក់ចំណូលកើនឡើងដូច្នេះក្តី អ្នករត់ម៉ូតូឌុបភាគច្រើនបានត្អូញត្អែរពីបញ្ហាសាំងឡើងថ្លៃ ។ ៨៥% នៃអ្នករត់ម៉ូតូឌុបឆ្លើយសំភាសន៍ មិនមានលទ្ធភាពសន្សំប្រាក់ដើម្បីចាប់យកអាជីពថ្មីទេ ពីព្រោះ ប្រាក់ចំណូលនេះគ្រប់គ្រាន់សំរាប់តែផ្គត់ផ្គង់ជីវភាពគ្រួសារប៉ុណ្ណោះ ។

ប្រាក់ចំណូលពិតប្រចាំថ្ងៃរបស់អ្នកលក់បន្លែតូចតាចគឺ ៨៣០៣រៀល រឺកើន ៣៦% ធៀបនឹងខែវិច្ឆិកា ២០០៦ ។ អ្នកលក់បន្លែតូចតាចនៅភ្នំពេញ ៤៨% ធ្វើចំណាកស្រុកមកពីតំបន់ជនបទ។ ក្នុងចំណោមអ្នកចំណាកស្រុកទាំងនោះ ៩០% បានជួលផ្ទះគេស្នាក់នៅ ដោយត្រូវចំណាយប្រហែល ២០.០០០រៀល/ខែ លើឈ្នួលផ្ទះ ហើយ ១០% ផ្សេងទៀត ស្នាក់នៅជាមួយសាច់ញាតិនៅភ្នំពេញ។

នៅខែវិច្ឆិកា ២០០៧ ប្រាក់ចំណូលពិតប្រចាំថ្ងៃរបស់អ្នករើសអេតចាយ កើន ៤២% ធៀបនឹងឆ្នាំមុន ដល់ ៥៥៦០រៀល ដែលបណ្តាលមកពីការឡើងថ្លៃរបស់អេតចាយ ។ ទោះបីមានកំណើនបែបនេះក្តី ក៏អ្នករើសអេតចាយនៅតែរកមួយថ្ងៃ ហូបមួយថ្ងៃដដែល ។ លើសពីនេះទៀត

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

អ្នកឆ្លើយសំភាសន៍ ចំនួន ៣២% មានជំពាក់បំណុលគេ ដោយសារត្រូវខ្ចីប្រាក់សំរាប់ទិញបាយហូប រឺ ចំណាយព្យាបាលជំងឺ ។

នៅខែវិច្ឆិកា អ្នកធាក់ស៊ីក្លូនៅភ្នំពេញ រកចំណូលបានច្រើនជាងពេលឯទៀតខ្លាំងណាស់ ដោយសារមានមនុស្សកុះករនៅទីក្រុង ដើម្បីចូលរួមពិធីបុណ្យអុំទូក ។ នៅខែនេះ ប្រាក់ចំណូលរបស់អ្នកធាក់ស៊ីក្លូកើន ២៧% ធៀបនឹងខែវិច្ឆិកា ២០០៦ ។

ប្រាក់ចំណូលពិតប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែកើន ៣% ដល់ ៤៧៩០រៀល ។ អ្នកឆ្លើយសំភាសន៍ ៨២% រាយការណ៍ថា ចលនាផ្លាស់ទីរបស់យុវជនក្មេងៗដើម្បីមកធ្វើការនៅតំបន់ទីក្រុង បានធ្វើអោយខ្វះកំលាំងពលកម្មធ្វើស្រែ ដែលនាំអោយឡើងថ្លៃឈ្នួលពលកម្ម ។ ប៉ុន្តែពលករ ៨៥% ត្អូញត្អែរថា នៅតែរកមួយថ្ងៃហូបមួយថ្ងៃដដែល ។

ប្រាក់ចំណូលរបស់អ្នកបំរើតាមភោជនីយដ្ឋានស្រី/ប្រុស នៅថេរធៀបនឹងឆ្នាំមុន។ អ្នកបំរើស្រី/ប្រុសភាគច្រើន ធ្វើចំណាកស្រុកពីខេត្តនានាក្នុងនេះ ៨៥% ស្នាក់នៅជាមួយម្ចាស់ភោជនីយដ្ឋាន ហើយអ្នកនៅសល់គឺជួលផ្ទះគេស្នាក់នៅ ។

នៅខែវិច្ឆិកា ២០០៧ ប្រាក់ចំណូលពិតប្រចាំថ្ងៃរបស់កម្មករសំណង់មានជំនាញកើនដល់ ១០.៩៥៦រៀល រឺកើន ៧% ធៀបនឹងឆ្នាំ២០០៦ ។ អ្នកឆ្លើយសំភាសន៍ ៩៧% បានរាយការណ៍ថា សកម្មភាពសាងសង់នៅទីក្រុងកើនយ៉ាងខ្លាំង ដែលនាំអោយតំរូវការកម្មករកើនឡើង ។ ប៉ុន្តែផលិតផលនានាឡើងថ្លៃច្រើនជាងកំណើនប្រាក់ចំណូលទៅទៀត ដែលធ្វើអោយកម្មករឆ្លើយសំភាសន៍ ១៣% ត្រូវជំពាក់បំណុលគេ ។

ប្រាក់ចំណូលពិតរបស់កម្មករកាត់ដេរថយចុះ ៨% មកត្រឹម ៨២០៧ រៀល ។ កម្មករឆ្លើយសំភាសន៍ ៦៧% បានរាយការណ៍ថា ការធ្លាក់ចុះនេះបណ្តាលពីម៉ោងធ្វើការថយចុះ ។ កម្មករកាត់ដេរ ២៦% បានប្រាប់ថាបន្ទាប់ពីដោះស្រាយចំណាយលើតំរូវការផ្ទាល់ខ្លួនហើយ ពួកគេមានលុយសល់មួយចំនួនតូចសំរាប់ផ្ញើទៅក្រុមគ្រួសារ ។ កំណើនឧស្សាហកម្មនៅតំបន់ទីក្រុងបានទាក់ទាញប្រជាជនពីតំបន់ជនបទ ពិសេសយុវជនក្មេងៗ ដែលយ៉ាងហោចណាស់ ៩០% នៃកម្មករកាត់ដេរបានធ្វើចំណាកស្រុកពីតំបន់ជនបទហើយពួកគេភាគច្រើនមានដីស្រែតិចជាងមួយហិកតា ។

*រៀបរៀងដោយ ផាន់ ដាលីស និងប៊ុន ដូរីណា*


## Cambodia Development Review—2008 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to:
Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❒Mr ❒Ms ❒Dr ❒Other ..........
First name: .......... Last name: .......... Position: ..........
Organisation / Company: ..........
Address (CCC Box if applicable): ..........
City / Province: .......... Country: ..........
Telephone: .......... Fax: ..........
e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Do not send cash through the post.
Please inform the Publishing Department at CDRI if your contact details change.

# តាមដានសេដ្ឋកិច្ច ~ សន្ទស្សន៍សេដ្ឋកិច្ច

## តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០១-២០០៧

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | |
| កសិកម្ម | 0.4 | 40.3 | 3.7 | 12.3 | 26.8 | 126.5 | 216.9 | 0.0 | 154.6 | 19.1 | 2.1 | 12.0 |
| ឧស្សាហកម្ម | 105.2 | 67.7 | 137.2 | 187.9 | 914.6 | 40.1 | 76.9 | 171.7 | 76.6 | 142.7 | 51.2 | 187.2 |
| កាត់ដេរ | 26.5 | 27.2 | 68.1 | 132.6 | 174.4 | 30.5 | 9.6 | 23.2 | 26.1 | 36.6 | 24.3 | 40.7 |
| សេវាកម្ម | 118.4 | 145.3 | 168.4 | 91.8 | 155.5 | 60.7 | 2,043.2 | 94.5 | 740.7 | 335.7 | 138.0 | 957.7 |
| សណ្ឋាគារ និងទេសចរណ៍ | 73.8 | 47.1 | 124.1 | 55.9 | 102.6 | 0.0 | 26.2 | 3.5 | 315.3 | 140.3 | 55.0 | 653.8 |
| សរុប | 224.0 | 253.3 | 309.3 | 292.0 | 1096.9 | 227.3 | 2,337.0 | 266.2 | 971.9 | 497.5 | 191.3 | 1156.9 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | 90.7 | 928.1 | -88.6 | 265.1 | -48.8 | -61.6 | 504.7 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | -16.8 | 13.1 | 22.1 | -5.6 | 275.6 | -52.2 | 2331.2 | -34.1 | 715.4 | 118.9 | 91.8 | 334.6 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០១-២០០៧

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2* | Q3 |
| | | | | | | លានដុល្លារ | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 15.9 | 23.4 | 20.0 | 30.3 | 45.5 | 10.1 | 5.7 | 7.6 | 9.7 | 14.4 | 22.8 | 21.7 |
| ផ្ទះល្វែង | 167.8 | 179.9 | 91.6 | 167.6 | 204.2 | 39.9 | 51.8 | 67.1 | 54.5 | 88.9 | 33.2 | 117.5 |
| ផ្សេងៗ | 12.6 | 16.6 | 87.3 | 65.6 | 109.1 | 17.4 | 24.7 | 20.8 | 13.9 | 35.9 | 88.8 | 40.6 |
| សរុប | 196.3 | 219.9 | 198.9 | 263.5 | 358.8 | 67.4 | 82.2 | 95.5 | 78.2 | 139.2 | 144.7 | 179.7 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | -6.2 | 22.2 | 16.1 | -18.1 | 78.0 | 3.9 | 24.2 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | -4.4 | 12.0 | -9.5 | 32.5 | 36.2 | -36.5 | -21.2 | 24.8 | 8.9 | 106.5 | 76.0 | 88.2 |

** Revised data. Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ២០០១-២០០៧

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | លានដុល្លារ | | | | | | |
| ការនាំចេញសរុប | 1268.2 | 1453.2 | 1708.1 | 2108.1 | 2352.8 | 603.2 | 652.5 | 807.5 | 736.7 | 707.8 | 705.0 | 890.8 |
| រួមមាន: សំលៀកបំពាក់ | 1202.2 | 1355.8 | 1628.4 | 2027 | 2253.3 | 568.5 | 632.4 | 782.0 | 716.0 | 677.5 | 688.2 | 846.1 |
| - ទៅសហរដ្ឋអាមេរិក | 840.9 | 943.4 | 1099.8 | 1270.9 | 1546.1 | 402.5 | 438.6 | 522.8 | 483.2 | 499.1 | 451.2 | - |
| - ទៅសហគមន៍អ៊ឺរ៉ុប | 323.3 | 356.3 | 414.7 | 590.8 | 503.1 | 110.6 | 142.2 | 188.1 | 160.1 | 106.3 | 163.1 | - |
| - ប្រទេសផ្សេងទៀត | 38.0 | 56.1 | 113.8 | 165.3 | 204.1 | 55.3 | 51.6 | 71.0 | 72.8 | 72.0 | 73.8 | - |
| កសិកម្ម | 66.0 | 97.3 | 79.7 | 81.2 | 99.5 | 34.7 | 20.2 | 25.5 | 20.7 | 30.3 | 16.8 | - |
| - កៅស៊ូ | 25.9 | 29.7 | 35.1 | 38.3 | 36.7 | 7.8 | 9.8 | 13.6 | 10.2 | 8.4 | 6.9 | 11.7 |
| - ឈើ | 22.3 | 16.0 | 10.2 | 11.1 | 10.3 | 2.1 | 2.3 | 2.5 | 1.7 | 2.1 | 2.0 | 0.0 |
| - ត្រី | 6.0 | 4.3 | 2.8 | 10.6 | 10.1 | 1.9 | 1.0 | 1.6 | 1.4 | 0.7 | 0.4 | 1.2 |
| - ផ្សេងៗ | 11.8 | 47.4 | 31.6 | 21.3 | 42.6 | 22.9 | 7.0 | 7.7 | 7.5 | 19.0 | 7.5 | - |
| ការនាំចូលសរុប | 1501.4 | 1707.8 | 1824.9 | 2149.0 | 2513 | 690.7 | 774.9 | 784.3 | 807.1 | 790.9 | 911.6 | 924.5 |
| រួមមាន: ផលិតផលប្រេងកាត | 154.4 | 157.5 | 191.6 | 187.0 | 184.8 | 57.6 | 59.8 | 62.4 | 58.7 | 66.5 | 68.5 | 71.0 |
| - សាំង | - | 25.9 | 33.2 | 30.2 | 40.2 | 10.9 | 12.4 | 13.1 | 13.2 | 15.7 | 20.2 | - |
| - ម៉ាស៊ូត | - | 100.8 | 109.6 | 109.4 | 93.1 | 32.5 | 32.2 | 30.1 | 27.2 | 31.9 | 36.6 | - |
| សំភារៈសំណង់ | - | 12.9 | 80.8 | 95.3 | 134.7 | 37.0 | 39.1 | 42.5 | 35.8 | 44.1 | 31.6* | 34.9 |
| ផ្សេងៗ | - | 1568.2 | 1601.3 | 1914.0 | 2245 | 610.3 | 691.2 | 698.5 | 731.0 | 699.2 | 807.5 | 818.6 |
| ជញ្ជីងពាណិជ្ជកម្ម | -233.2 | -254.6 | -116.8 | -40.9 | -160.1 | -87.5 | -122.4 | 23.2 | -70.4 | -83.1 | -208.1 | -30.7 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | -5.4 | 39.8 | -118.9 | -403.4 | 18.0 | 150.4 | -85.2 |
| ការនាំចេញសរុប | - | - | - | - | - | -6.4 | 8.2 | 23.7 | -8.8 | -3.9 | 0.4 | 26.4 |
| ការនាំចូលសរុប | - | - | - | - | - | -0.03 | 12.2 | 1.2 | 2.9 | -2.0 | 15.3 | 1.4 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 24.9 | 9.2 | -54.1 | -64.9 | 291.4 | 51.1 | -19.5 | -76.2 | 52.0 | -5.0 | 70.0 | -232.3 |
| ការនាំចេញសរុប | 20.1 | 14.6 | 17.5 | 23.4 | 11.6 | 30.3 | 26.7 | 10.6 | 14.3 | 17.3 | 8.0 | 10.3 |
| ការនាំចូលសរុប | 5.9 | 13.7 | 6.9 | 17.8 | 16.9 | 32.6 | 16.2 | 24.0 | 16.8 | 14.5 | 17.6 | 17.9 |

*Import data include tax-exempt imports. * Q2 revision. Sources: Customs and Excise Department, cited by NBC*

### តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០១-២០០៧

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | |
| តាមផ្លូវអាកាស | 408.4 | 523.0 | 456.0 | 626.1 | 856.5 | 275.4 | 204.4 | 224.2 | 325.0 | 373.6 | 275.6 | 278.5 |
| តាមផ្លូវគោក និងទឹក | 196.5 | 263.5 | 245.0 | 428.9 | 565.1 | 181.9 | 153.6 | 146.4 | 191.0 | 177.2 | 148.9 | 153.3 |
| សរុប | 604.9 | 786.5 | 701.1 | 1055.0 | 1421.6 | 457.3 | 358.0 | 370.6 | 516.0 | 550.8 | 424.5 | 431.8 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | 9.9 | -21.7 | 4.1 | 39.2 | 6.7 | -22.9 | 1.7 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 29.7 | 30.0 | -10.9 | 50.5 | 34.7 | 20.2 | 21.2 | 14.7 | 24.1 | 20.4 | 19.2 | 16.5 |

*Source: Ministry of Tourism.*

### តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០០-២០០៧ (ពាន់លានរៀល)

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 1528 | 1530 | 1744 | 1764 | 2126 | 2625 | 595.9 | 731.5 | 732.2 | 1199.6 | 824.9 | 1016.8 |
| ចំណូលចរន្ត | - | 1521 | 1728 | 1733 | 2107 | 2474 | 593.2 | 726.9 | 716.8 | 844.9 | 824.9 | 1012.4 |
| ចំណូលពន្ធ | 1096 | 1096 | 1227 | 1220 | 1577 | 1911 | 484.7 | 558.6 | 565.8 | 661.8 | 699.9 | 887.7 |
| ពន្ធគយ | 376 | 376 | 424 | 395 | 513 | 573 | 135.5 | 151.7 | 157.2 | 200.0 | - | - |
| ពន្ធក្នុងស្រុក | - | - | - | - | - | - | - | - | - | - | 487.9 | 642.1 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | - | - | - | - | - | - | 212.1 | 245.6 |
| ចំណូលមិនមែនពន្ធ | 424 | 424 | 501 | 513 | 530 | 563 | 108.5 | 168.3 | 151.0 | 183.1 | 125.0 | 124.7 |
| អាជីវកម្មព្រៃឈើ | 28 | 29 | 15 | 7 | 2 | 3 | 0.5 | 0.7 | 0.3 | 0.9 | - | - |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 124 | 122 | 123 | 120 | 94 | 123 | 11.4 | 30.0 | 11.7 | 30.0 | - | - |
| ចំណូលលើអចលនទ្រព្យ | - | - | - | - | - | - | - | - | - | - | 27.9 | 15.5 |
| លក់ទំនិញ និងសេវា | - | - | - | - | - | - | - | - | - | - | 88.8 | 93.0 |
| ចំណូលជាមូលធន | 8 | 9 | 16 | 31 | 19 | 152 | 2.7 | 4.6 | 15.4 | 354.7 | 0.0 | 4.5 |
| ចំណាយសរុប | 2332 | 2332 | 2948 | 2757 | 2932 | 3295 | 932.1 | 1020.1 | 1030.6 | 1191.9 | 923.9 | 1098.7 |
| ចំណាយជាមូលធន | 976 | 977 | 1388 | 1171 | 1163 | 1328 | 390.5 | 394.7 | 423.8 | 429.1 | 367.1 | 408.1 |
| ចំណាយចរន្ត | 1356 | 1355 | 1560 | 1586 | 1769 | 1967 | 541.7 | 625.4 | 606.9 | 762.8 | 556.8 | 681.6 |
| អប់រំ និងសុខាភិបាល | 344 | 343 | 454 | 473 | 518 | 351 | 80.3 | 202.3 | 150.1 | 281.3 | - | - |
| ការពារជាតិ និងសន្តិសុខជាតិ | 404 | 405 | 438 | 411 | 423 | 451 | 78.1 | 116.7 | 155.3 | 170.1 | - | - |
| ក្រសួងផ្សេងៗទៀត | 636 | 637 | 668 | 702 | 828 | 1165 | 383.2 | 306.4 | 301.5 | 311.4 | - | - |
| បៀវត្សរ៍ | 517 | 509 | 587 | 615 | 640 | 711 | 140.5 | 210.3 | 230.6 | 240.6 | 199.7 | 242.7 |
| ឧបត្ថម្ភធន និង ជំនួយសង្គមកិច្ច | - | - | - | - | - | - | - | - | - | - | 61.9 | 184.0 |
| សមតុល្យជាទូទៅ | -804 | -802 | -1204 | -993 | -806 | -706 | -336.3 | -288.5 | -298.5 | 7.7 | -99.0 | -81.9 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 768 | 766 | 1249 | 886 | 864 | 1127 | 308.0 | 341.3 | 335.2 | 376.2 | 344.0 | 313.9 |
| ហិរញ្ញប្បទានក្នុងស្រុក | 36 | 37 | -45 | 106 | 148 | -396 | 28.3 | -52.8 | -36.7 | -383.9 | -245.0 | -213.0 |

*Provisional for 2007. The third quarter data are not yet available. Source: MEF web site*

### តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០០១-២០០៧

| (October-December 2006:100) | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | |
| ខេត្ត | - | - | - | - | - | - | - | - | - | 5.9 | 9.0 | 14.4 |
| ភ្នំពេញ | - | - | - | - | - | - | - | - | - | 4.7 | 5.8 | 7.7 |
| កម្ពុជា - ទំនិញគ្រប់ប្រភេទ | - | - | - | - | - | - | - | - | - | 5.7 | 8.5 | 11.9 |
| - មហូបអាហារ | - | - | - | - | - | - | - | - | - | 8.3 | 12.0 | 16.9 |
| - ដឹកជញ្ជូន | - | -- | - | - | - | - | - | - | - | -3.4 | 1.1 | 2.0 |
| | | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | |
| រៀលក្នុង ១ ដុល្លារ* | 3916.3 | 3912.1 | 3973.3 | 4016.3 | 4119.7 | 4,094.8 | 4106.6 | 4145.3 | 4129.4 | 4063.0 | 4075.4 | 4082.3 |
| រៀលក្នុង ១ បាតថៃ* | 88.2 | 91.1 | 95.8 | 99.9 | 102.6 | 103.5 | 108.0 | 110.3 | 113.0 | 113.7 | 118.0 | 130.0 |
| រៀលក្នុង ១០០ ដុងវៀតណាម* | 26.6 | 25.6 | 25.6 | 25.5 | 25.8 | 25.4 | 25.0 | 24.9 | 25.0 | 24.6 | 24.7 | 25.3 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 32.8 | 36.8 | 41.4 | 46.3 | 54.0 | 64.2 | 72.2 | 73.0 | 72.8 | 77.7 | 79.8 | 80.8 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1329 | 1521 | 1508 | 2088 | 2633 | 2867 | 3110 | 3333 | 3250 | 3067 | 3100 | 3203 |
| ថ្លៃសាំង (រៀល/លីត្រ) | 2113 | 2084 | 2150 | 2833 | 3442 | 3767 | 4000 | 4200 | 4050 | 3750 | 3900 | 4002 |

Sources: CDRI, NIS and NBC

### តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០១-២០០៧ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ពាន់លានរៀល | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 3080 | 3737 | 4027 | 4797 | 5475 | 6410 | 6682 | 6958 | 7224 | 8056 | 9048 | 9768 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -876 | -849 | -698 | -467 | -450 | -699 | -637 | -497 | -282 | -263 | -172 | 140 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -75 | -119 | -128 | -209 | -421 | -755 | -831 | -892 | -953 | -1176 | -1403 | -1547 |
| ឥណទានដល់ផ្នែកឯកជន | 936 | 1059 | 1337 | 1817 | 2394 | 2,778 | 2997 | 3288 | 3628 | 4066 | 4537 | 5376 |
| រូបិយវត្ថុទូទៅ M2 | 2204 | 2888 | 3329 | 4330 | 5025 | 5711 | 6045 | 6461 | 6942 | 7793 | 8876 | 9908 |
| រូបិយវត្ថុ M1 | 609 | 813 | 937 | 1153 | 1323 | 1449 | 1512 | 1563 | 1658 | 1794 | 1748 | 1750 |
| រូបិយវត្ថុផ្សេងៗ | 1595 | 2075 | 2392 | 3177 | 3702 | 4262 | 4533 | 4898 | 5285 | 5999 | 7128 | 8158 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| រូបិយវត្ថុទូទៅ M2 | 20.4 | 31.0 | 15.2 | 30.0 | 16.1 | 27.0 | 30.6 | 29.4 | 38.2 | 36.5 | 46.8 | 53.4 |
| រូបិយវត្ថុ M1 | 12.8 | 33.5 | 15.3 | 23.0 | 14.7 | 20.9 | 24.4 | 22.2 | 25.3 | 23.9 | 15.7 | 12.0 |
| រូបិយវត្ថុផ្សេងៗ | 23.6 | 30.0 | 15.2 | 32.8 | 16.6 | 33.6 | 32.8 | 31.9 | 42.7 | 40.7 | 57.3 | 66.5 |

Source: National Bank of Cambodia

# តាមដានសេដ្ឋកិច្ច ~ សន្ទស្សន៍សេដ្ឋកិច្ច

*តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ ( ថ្លៃថេរ ខែវិច្ឆិកា ២០០០)*

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 វិច្ឆិកា | 2003 | 2004 | 2005 | 2006 វិច្ឆិកា | 2007 កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | 2007 ឧសភា | សីហា | វិច្ឆិកា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 7393 | 6534 | 9245 | 7126 | 9393 | 8 | 18 | 27 |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 7045 | 6010 | 9798 | 7704 | 8852 | 33 | 47 | 26 |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 6125 | 6125 | 8951 | 9116 | 8303 | 38 | 75 | 36 |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 3903 | 4530 | 5533 | 6038 | 5560 | 23 | 42 | 42 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4498 | 4078 | 5150 | 4193 | 4508 | 21 | -2 | 0 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4653 | 4126 | 4531 | 4561 | 4790 | 0 | 10 | 3 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 8957 | 11146 | 8347 | 9033 | 8207 | 6 | -2 | -8 |
| អ្នករត់ម៉ូតូឌុប | 8610 | 10092 | 9204 | 8201 | 8386 | 9144 | 12,886 | 8979 | 13,060 | 47 | 33 | 37 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 6028 | 5263 | 6075 | 5901 | 7550 | -5 | -2 | 43 |
| កម្មករសំណង់មានជំនាញ | 13,127 | 13,111 | 12,679 | 10,316 | 9466 | 10,215 | 11,892 | 11,723 | 10,956 | 21 | 24 | 7 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

## *តទៅទំព័រទី ២៤* ព័ត៌មានថ្មីៗ ពី...

ពលករ និងទីភ្នាក់ងារពាក់ព័ន្ធផ្សេងៗទៀត ។ ការសិក្សាស្វែងរកការពិតស្តីពីវិនិយោគទុនចិននៅកម្ពុជា បានចាប់ផ្តើមនៅខែកុម្ភៈ ហើយលទ្ធផលដំបូងនឹងទទួលបានក្នុងរយៈពេលមួយឆ្នាំខាងមុខ ។ ការសិក្សាឯកសារស្រាវជ្រាវស្តីពីពាណិជ្ជកម្ម និងបរិស្ថាន ដែលស្ថិតក្នុងគំរោងមួយមានរយៈពេលមួយឆ្នាំក៏បានបញ្ចប់រួចរាល់ដែរ ។ នៅចុងខែកុម្ភៈ លោក សាំង ច័ន្ទហង្ស បានចូលបំរើការជាអ្នកស្រាវជ្រាវក្នុងផ្នែកនេះ ។

ចាប់ពីដើមឆ្នាំ២០០៨ ផ្នែកសន្តិសុខមនុស្ស និងការកសាងសន្តិភាព បានចាប់ផ្តើមកំនត់វិស័យស្រាវជ្រាវថ្មីរបស់ខ្លួន ។ វិស័យដ៏ល្អមួយ គឺចំណងទាក់ទងជាយថាហេតុរវាងការគំរាមកំហែងដល់មនុស្ស/ភាពក្រីក្រ និងបញ្ហាចោទខាងអភិបាលកិច្ច ការប្រើប្រាស់ធនធានធម្មជាតិ និងសុខមាលភាពសេដ្ឋកិច្ចរបស់បុគ្គលម្នាក់ៗ ។ នៅខែមីនា ផ្នែកនេះបានដាក់សំណើមួយទៅ UNICEF ដើម្បីសិក្សាពីស្ថានភាពយុវជន ហើយទទួលបានកិច្ចព្រមព្រៀងមួយរវាង CDRI និង UNICEF រួចហើយ ។ ផ្នែកនេះក៏កំពុងរង់ចាំកិច្ចព្រមព្រៀងស្រេចបាច់របស់ UNICEF លើគំរោងសិក្សាពីភាពក្រីក្ររបស់កុមារនៅកម្ពុជា ដែលអាចត្រូវការឱ្យ CDRI ធ្វើជាអ្នកអនុវត្តគំរោងជាថ្មីម្តងទៀត ។ ម្យ៉ាងទៀត ផ្នែកសន្តិសុខមនុស្ស បានកសាងសំណើមួយទាក់ទង នឹងការស្រាវស្រាវលើការបោះឆ្នោត ដើម្បីស្នើដល់អ្នកផ្តល់ជំនួយមួយចំនួនដែលមានចំណាប់អារម្មណ៍ ដូចជា CIDA, AusAID និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ។

កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវការគ្រប់គ្រងធនធានទឹក (WRMRCDP) របស់ផ្នែកធនធានធម្មជាតិ និងបរិស្ថាន (NRE) បានបញ្ចប់ដំណាក់កាលសិក្សាទ្រឹស្តី និងការវាយតំលៃខាងសង្គមនៃការគ្រប់គ្រងធនធានទឹកនៅកម្ពុជា ។ NRE បានបង្ហើយសេចក្តីព្រាងរបាយការណ៍ដំបូងស្តីពីការវិភាគចំណាយនិងផលចំណេញ នៃការអភិវឌ្ឍចំការកៅស៊ូនៅកម្ពុជា ។ មិនតែប៉ុណ្ណោះ NRE កំពុងចុះអង្កេតដល់ទីកន្លែងសំរាប់គំរោងរួមគ្នាមួយស្តីពីព្រៃត្រពិកជួយកាត់បន្ថយភាពក្រីក្រ ដែលត្រូវវិភាគលើទិន្នន័យគ្រួសារ និងជាសាកលសំរាប់ ៥ប្រទេសផ្សេងគ្នា ។ NRE ក៏បានធ្វើចប់រួចរាល់នូវអង្កេតបរិស្ថានធម្មជាតិ និងសង្គម ដោយសហការជាដៃគូជាមួយក្រុមការងារមកពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) សំរាប់ការសិក្សាប្លង់មេនៃការអភិវឌ្ឍវារីអគ្គិសនីនៅកម្ពុជា ។ របាយការណ៍អង្កេតនេះ បានដាក់ជូន JICA រួចហើយ ។ នៅថ្ងៃ២៤-២៨ មីនា NRE បានរៀបចំវគ្គបណ្តុះបណ្តាលមួយ ស្តីពីសេដ្ឋកិច្ចបរិស្ថាននៅ CDRI ដែលបានទទួលជំនួយឧបត្ថម្ភពីកម្មវិធីបរិស្ថាន និងសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ (EEPSEA) និងមានអ្នកចូលរួមមកពី ស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសាកលវិទ្យាល័យរដ្ឋ និង ឯកជននានា ។

ផ្នែកភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ កំពុងបន្តសិក្សាពីចលនានៃភាពក្រីក្រ ។ អង្កេតមូលដ្ឋានស្តីពីផលិតផលកសិកម្ម និងជំនួញ ដែលជាផ្នែកមួយនៃគំរោងស្រាវជ្រាវរបស់បណ្តាញវិភាគអភិវឌ្ឍន៍ (DAN) បានចប់រួចរាល់នៅដើមឆ្នាំ២០០៨ ហើយការងារវិភាគលទ្ធផល និងសរសេររបាយការណ៍ កំពុងដំណើរការទៅមុខ ។ ផ្នែកនេះ គឺជាអ្នកអនុវត្តមួយក្រុមនៅក្នុងគំរោងកសាងសមត្ថភាពសហគមន៍ សំរាប់ការផ្តួចផ្តើមគំនិតកាត់បន្ថយភាពក្រីក្រនៅតំបន់អាងទន្លេសាប ដែលផ្តល់ថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ ដៃគូផ្សេងៗទៀតក្នុងគំរោងនេះគឺមាន វិទ្យាស្ថាន សិក្សាពីការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ (CBNRM-LI) និង ក្រុមប្រឹក្សាសំរាប់ការអភិវឌ្ឍកសិកម្ម និងជនបទ (CARD) ។ គំរោង នេះចាប់ផ្តើមនៅខែកុម្ភៈ ដោយមានរយៈពេលបំផុសគំនិត ៦ខែ ដែលក្នុងនោះ ស្ថាប័នអនុវត្តគំរោងទាំងអស់ ជាពិសេស CDRI និង CBNRM-LI ត្រូវកសាងផែនការការងារលំអិតសំរាប់គំរោងទាំងមូល ដូចជា គំរោងថវិកា ការវាយតំលៃពីតំរូវការបណ្តុះបណ្តាល ព្រមទាំងកំណត់ប្រធានបទត្រូវសិក្សា និងតាក់តែងវិធីសាស្រ្តសំរាប់ធ្វើអង្កេតមូលដ្ឋាន ។ វិទ្យាស្ថាន CDRI បានចុះហត្ថលេខា លើឯកសារកិច្ចព្រមព្រៀងគ្រប់គ្រងជាដៃគូមួយ សំរាប់ការគ្រប់គ្រងគំរោងស្វែងយល់ពីលំហូរសត្វចិញ្ចឹម និងគ្រោះថ្នាក់នៃការចំលង ជំងឺសត្វឆ្លងកាត់ព្រំដែនដែលទទួលថវិកាពី មជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ។ សកម្មភាពស្រាវជ្រាវជាក់លាក់នានាសំរាប់គំរោងនេះ នឹងត្រូវកំណត់ ហើយព្រមព្រៀងគ្នាដោយភាគីទាំងពីរនៅក្នុងអំឡុងពេលដំណើរការគំរោង ។